**LOWELL PUBLIC SCHOOLS**
ការិយាល័យរដ្ឋបាលកណ្តាល Henry J. Mroz
155 Merrimack Street
Lowell, MA 01852

ថ្ងៃទី 25 ខែ មករា ឆ្នាំ 2021

## បច្ចុប្បន្នភាពស្តីពីស្ថានភាពនៃការរៀនសូត្រដោយផ្ទាល់

ជូនចំពោះសិស្ស ក្រុមគ្រួសារ និង បុគ្គលិករបស់សង្កាត់សាលា Lowell Public Schools ទាំងអស់៖

ខណៈដែលយើងបន្តរៀបផែនការសម្រាប់ការត្រលប់ទៅកាន់ការរៀនសូត្រដោយផ្ទាល់ឡើងវិញប្រកបដោយសុវត្ថិភាពនោះ គណៈកម្មាធិការសាលាបានរៀបចំកិច្ចប្រជុំមួយជាមួយនឹងគណៈកម្មការសុខភាពក្រុង Lowell កាលពីថ្ងៃ ចន្ទ ទី 25 ខែ មករា ដើម្បីពិភាក្សាពីស្ថានភាពបច្ចុប្បន្ននៃជំងឺ COVID-19 នៅទីនេះក្នុងក្រុង Lowell ។

បន្ទាប់ពីបានថ្លឹងថ្លែងនូវគ្រប់កត្តាទាំងអស់ ដែលរួមមាននិន្នាការថ្មីបំផុតនៅក្នុងទិន្នន័យក្នុងមូលដ្ឋានស្តីពីជំងឺ COVID-19 និង ហានិភ័យសុវត្ថិភាព និង សុខភាពដែលពាក់ព័ន្ធសម្រាប់សិស្ស បុគ្គលិក និង សហគមន៍ធំទូលាយជាងនេះទៀតនោះ គណៈកម្មាធិការសាលាបានបោះឆ្នោតពន្យាពេលកាលបរិច្ឆេទគោលដៅទីមួយ ដែលនឹងត្រូវចាប់ផ្តើមឲ្យសិស្សត្រលប់មកកាន់ការបង្ហាត់បង្រៀនដោយផ្ទាល់វិញចាប់ពីថ្ងៃទី 1 ដល់ថ្ងៃទី 22 ខែ កម្ភៈ។

ហេតុនេះហើយ គ្រប់សិស្សរបស់សង្កាត់សាលា Lowell Public Schools ទាំងអស់នឹងបន្តស្ថិតនៅក្នុងការរៀនសូត្រពីចម្ងាយយ៉ាងហោចណាស់ពេញមួយសប្តាហ៍វិស្សមកាលនៃខែ កុម្ភៈ ដោយមានការកែប្រែកាលបរិច្ឆេទគោលដៅដូចតទៅនេះសម្រាប់ការឲ្យសិស្សវិលត្រលប់ទៅកាន់ការបង្ហាត់បង្រៀនដោយផ្ទាល់ឡើងវិញ៖

- ថ្ងៃទី 22 ខែ កុម្ភៈ - សិស្សនៅក្នុងកម្មវិធីអប់រំពិសេសដាច់ដោយឡែក ដែលពីមុនកំពុងចូលរួមក្នុងមធ្យោបាយរៀនសូត្រដោយផ្ទាល់របស់យើង
- ថ្ងៃទី 1 ខែ មីនា - សិស្ស ដែលមិនស្ថិតនៅក្នុងកម្មវិធីអប់រំពិសេសដាច់ដោយឡែកភាគច្រើន ប៉ុន្តែពីមុនបានរៀនដោយផ្ទាល់នៅក្នុងឆ្នាំសិក្សានេះ ជាផ្នែកមួយនៃផែនការបើកបវេសនកាលឡើងវិញដើមដំបូងរបស់យើង
- ថ្ងៃទី 1 ខែ មេសា - ការពង្រីកមធ្យោបាយរៀនសូត្រដោយផ្ទាល់របស់យើងដើម្បីរួមបញ្ចូលសិស្សបន្ថែមទៀត ក្រៅពីអ្នកដែលត្រូវបានចាត់តាំងឲ្យរៀនសូត្រដោយផ្ទាល់តាំងពីពេលចាប់ផ្តើមនៃឆ្នាំសិក្សានេះ

វាសំខាន់ណាស់ដើម្បីបញ្ជាក់ឡើងវិញថា កាលបរិច្ឆេទទាំងនេះមិនត្រូវបានកំណត់ដោយមិនអាចកែប្រែបាននោះទេ។ យើងនឹងបន្តពិនិត្យមើលលើទិន្នន័យពីជំងឺ COVID-19 និង ប្រឹក្សាជាមួយនឹងគណៈកម្មការសុខភាព ហើយយើងប្រាកដជានឹងផ្តល់ជូនអ្នកនូវបច្ចុប្បន្នភាពណាមួយ ខណៈពេលដែលយើងកំពុងសម្លឹងមើលផែនការរៀនសូត្ររបស់យើងដំណើរការទៅមុខនោះ។

យើងនៅតែសូមអរគុណចំពោះភាពជាដៃគូ និង ភាពអាចបត់បែនតាមកាលៈទេសៈរបស់អ្នក ស្របពេលដែលយើងខំប្រឹងឆ្លងកាត់ការបន្តនូវភាពមិនប្រាកប្រជានៃវិបត្តិសុខភាពមិនធ្លាប់មានមួយនេះ។

ដោយក្តីស្មោះស្ម័គ្រពី

បណ្ឌិត Joel D. Boyd
អ្នកគ្រប់គ្រងសង្កាត់សាលា